**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ...៤៥...អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពី**
**ការបង្កើតអង្គភាពសេនាតេជោ**
**ចំណុះអគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស នៃក្រសួងការពារជាតិ**
**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៨ ស្តីពីការបង្កើតអគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**មាត្រា១** .-

ត្រូវបានបង្កើតអង្គភាពសេនាតេជោ ចំណុះអគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស នៃក្រសួងការពារជាតិ មានកម្រិតស្មើនាយកដ្ឋាន។

ហ៊ុន

**មាត្រា២ .-**

អង្គភាពសេនាតេជោ នៃអគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេសមានតួនាទីធ្វើជាសេនាធិការជូនអគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេសលើវិស័យសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ស្ថាបត្យកម្ម ការងាររដ្ឋបាល កិច្ចសហប្រតិបត្តិការ និងសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសម្រាប់ វិមានឈ្នះ ឈ្នះ និងមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រង និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ សំណង់ និងថែរក្សាការពារឱ្យបានគង់វង្ស
- គ្រប់គ្រង ធានាសន្តិសុខ សណ្តាប់ធ្នាប់ និងធ្វើជាមគ្គុទេសជូនប្រតិភូជាតិ និងអន្តរជាតិដែលចូលមកទស្សនា
- សិក្សាស្រាវជ្រាវ ធ្វើបច្ចុប្បន្នភាពសារមន្ទីរវិមានឈ្នះ ឈ្នះ និងបណ្ណាល័យ
- គ្រប់គ្រង និងអភិវឌ្ឍន៍ ថែរក្សាប្រព័ន្ធបច្ចេកទេស បរិស្ថាន ជួសជុលរូបចម្លាក់ដែលមាននៅវិមានឈ្នះ ឈ្នះ
- រៀបចំគម្រោងថវិកា សម្រាប់ជួសជុល ថែទាំសំណង់វិមាន
- សម្របសម្រួលលិខិតស្នាមរដ្ឋបាលចេញ-ចូល គ្រប់ស្ថាប័ន អង្គភាពដែលមកទំនាក់ទំនងការងារ
- រៀបចំកម្មវិធីរំលឹកខួបវិមានឈ្នះ ឈ្នះ រៀងរាល់ឆ្នាំ និងកម្មវិធីបុណ្យប្រពៃណីជាតិផ្សេងៗ
- បូកសរុបលទ្ធផលការងារអង្គភាពសេនាតេជោ តាមព្រឹត្តិការណ៍ នីមួយៗ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- រៀបចំដៃគូសហប្រតិបត្តិការការងារផ្សេងៗ ដើម្បីផ្សព្វផ្សាយបទបញ្ហា អនុសាសន៍ និងគោលនយោបាយឈ្នះ ឈ្នះ
- សិក្សាស្រាវជ្រាវ ចងក្រង គ្រប់គ្រង និងកសាងស្តូបឈ្នះ ឈ្នះ នៅតាមបណ្តាតំបន់ប្រវត្តិសាស្ត្រនានា
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់លើប្រគល់ឱ្យ។

**មាត្រា៣ .-**

អង្គភាពសេនាតេជោ នៃអគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេសមានរចនាសម្ព័ន្ធចាត់តាំងដូចខាងក្រោម៖

- នាយក
- នាយករង
- លេខាធិការដ្ឋាន
- ការិយាល័យស្រាវជ្រាវ ហ្វឹកហ្វឺន បណ្តុះបណ្តាល
- ការិយាល័យស្ថាបត្យកម្ម
- ការិយាល័យសន្តិសុខសណ្តាប់ធ្នាប់
- ការិយាល័យអភិវឌ្ឍន៍ និងសមិទ្ធផល
- ការិយាល័យផ្សព្វផ្សាយ និងសហប្រតិបត្តិការ

**មាត្រា៤ .-**

តួនាទី ភារកិច្ច រចនាសម្ព័ន្ធ និងក្របខ័ណ្ឌចាត់តាំងលម្អិតអាស្រ័យដោយក្រសួងការពារជាតិកំណត់។

**មាត្រា៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

ជ៌

**មាត្រា៦** .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៧ កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្តេចពិជ័យសេនា ទៀ បាញ់**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៦
-រាជកិច្ច
-ឯកសារកាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ......៤៥ អនក្រ.បក......ចុះថ្ងៃទី..៣០..ខែ.....មីនា.......ឆ្នាំ២០២០

ស្តីពីរចនាសម្ព័ន្ធចាត់តាំងអង្គភាពសេនាតេជោ ចំណុះអគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស នៃក្រសួងការពារជាតិ

